សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

# សេចក្តីថ្លែងការណ៍

សហព័ន្ធស្រូវអង្ករកម្ពុជា មានការសោកស្តាយ និងហួសចិត្តជាខ្លាំង ចំពោះទង្វើថ្មីៗរបស់ជនអគតិមួយក្រុមតូច ដែលមានចេតនា និងមហិច្ឆតាអាក្រក់លើវិស័យស្រូវអង្ករកម្ពុជា ជាពិសេសទៅលើផលប្រយោជន៍របស់កសិករខ្មែរដែលទង្វើនេះត្រូវបានធ្វើឡើងដោយអតីតក្រុមសកម្មជនគណបក្សសង្គ្រោះជាតិ នៅក្នុងតំបន់មួយនៃប្រទេសអូស្ត្រាលីដែលដឹកនាំដោយ **ឈ្មោះ ខៀវ ដារ៉ា** ដែលបានតាំងខ្លួនថា ជាអ្នកតំណាងឱ្យពលរដ្ឋខ្មែរ-អូស្ត្រាលី ហើយបានដាក់ញត្តិទៅតំណាងរាស្ត្រអូស្ត្រាលីមួយរូបដោយបានចោទថា អង្កររបស់កម្ពុជាដែលបាននិងកំពុងនាំចេញទៅប្រទេសអូស្ត្រាលី មានការជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស។

នេះជាការប្រឌិតរឿងដែលគ្មានមូលដ្ឋាន និងទឡ្ហីករណ៍ការពិតណាបន្តិចសោះក្រៅពីការចង់បំផ្លាញផលប្រយោជន៍របស់ប្រទេសកម្ពុជា ជាពិសេសផលប្រយោជន៍របស់កសិករខ្មែរដែលតំណាងឱ្យប្រជាជនមួយភាគធំដែលជាកម្លាំងចលករនៃសេដ្ឋកិច្ច ហើយវិស័យស្រូវអង្ករនេះបាននឹងកំពុងផ្តល់ការងារជូនប្រជាជនកម្ពុជាប្រមាណជា ៣៧% ឬ ជាង៣.២លាននាក់ ក្នុងនោះស្ត្រីចំនួនជាង ១.៦លាននាក់ ស្របពេលដែលកម្ពុជាកំពុងទទួលរងនូវឥទ្ធិពលហានិភ័យជំងឺរាតត្បាតកូវីដ១៩ គ្រោះរាំងស្ងួតកាលពីពាក់កណ្តាលរដូវវស្សា និងគ្រោះទឹកជំនន់ទឹកភ្លៀងចុងរដូវវស្សា។

កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាកសិករក្នុងការដាំដុះដែលបានធ្វើឱ្យកិត្តិនាមនៃគ្រាប់អង្ករកម្ពុជាមានគុណភាព និងត្រូវបានទទួលស្គាល់ថា ជាអង្ករដែលល្អបំផុតលើពិភពលោកតាមរយៈពានរង្វាន់អង្ករល្អបំផុតផ្តាច់គេនៅលើពិភពលោក ( The World Best Rice ) ក្នុងឆ្នាំ ២០១២ ២០១៣ ២០១៤ និងឆ្នាំ ២០១៨។ **ការចោទប្រកាន់ដែលលើកឡើងដោយក្រុមអគតិមួយចំនួននោះគឺ ជាចេតនាអាក្រក់ក្នុងការបំផ្លាញកេរ្តិ៍ឈ្មោះអង្ករខ្មែរ និងមោទនភាពរបស់ប្រជាកសិករខ្មែរ។**

ប្រជាកសិករខ្មែរដែលជាម្ចាស់ស្រែជាង ២.៥ លានហិកតា ដែលជាមរតកទទួលបានពីការបែងចែកដោយសមធម៌ ក្រោយរបបប្រល័យពូជសាសន៍ត្រូវបានផ្តួលរំលំ ហើយដែលបានក្លាយជាមរតកប្រចាំគ្រួសារនីមួយៗនេះ ទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈការការពារ និងផ្តល់អត្ថប្រយោជន៍នានាជាក់ស្តែងលើការផ្តល់ប័ណ្ណគ្រប់គ្រងកម្មសិទ្ធិដីធ្លីច្បាស់លាស់ដល់ប្រជាកសិករជាម្ចាស់ស្រែដែលមិនអាចឱ្យជនណាមួយមករំលោភបំពាន ឬយកជាកម្មសិទ្ធិបានឡើយ ផ្ទុយពីអ្វីដែលពួកជនគ្មានមនសិការ និងអគតិមួយចំនួនបាននិងកំពុងតែប្រឌិតរឿងចង់បំផ្លាញកសិករខ្មែរ ដោយភ្ជាប់វិស័យស្រូវអង្ករខ្មែរជាមួយរឿងនយោបាយ។

ជាច្រើនឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានលើកលែងការបង់ពន្ធលើដីស្រែ និងពន្ធគ្រប់ប្រភេទលើធាតុចូលកសិកម្ម គ្រាប់ពូជកសិកម្ម សម្ភារៈ និងគ្រឿងយន្តកសិកម្ម ព្រមទាំងគោលនយោបាយអគ្គិសនីសម្រាប់កសិកម្មផងដែរ។



#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia. Tel: +855 23 559 8999 , +855 87 559 899. E-mail: info@crf.org.kh

លើសពីនេះទៅទៀត ដើម្បីជួយដល់លំនឹងជីវភាពកសិករ ជាពិសេសស្ថិរភាពទីផ្សារស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានជួយដល់កសិករ តាមរយៈកញ្ចប់ឥណទានពិសេស ផ្តល់ដល់រោងម៉ាស៊ីនកិនស្រូវក្នុងស្រុក តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដែលធ្វើឱ្យលំនឹងទីផ្សារស្រូវមានស្ថិរភាព និងមានតម្លៃសមរម្យសម្រាប់កសិករក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ ទោះបីជាស្ថានភាពទីផ្សារអង្ករបស់ពិភពលោកនៅក្នុងឆ្នាំ២០២០នេះ មានការធ្លាក់ចុះតម្លៃប្រមាណជា ២៥% យ៉ាងណាក្តី ក៏តម្លៃទីផ្សារស្រូវនៅកម្ពុជាសម្រាប់កសិករនៅតែមានតម្លៃសមរម្យ និងមិនបានធ្លាក់ចុះទៅតាមនិន្នាការនៃទីផ្សារអង្ករលើពិភពលោកនោះឡើយ។

ក្រៅពីកិច្ចខិតខំប្រជោមជ្រែងដោយផ្ទាល់ រាជរដ្ឋាភិបាលកម្ពុជាក៏បានបើកទូលាយដល់បណ្តាប្រទេសជាមិត្តដែលមានកម្មវិធីអភិវឌ្ឍន៍ និងអង្គការអន្តរជាតិជាច្រើនឱ្យចូលរួមអភិវឌ្ឍន៍ក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលដែលក្នុងនោះក៏មានកម្មវិធីរបស់ប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីខ្សែសង្វាក់តំលៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) ផងដែរ។ ក្រៅពីនេះក៏មានអង្គការអន្តរជាតិនានាបានចូលរួមពង្រីកវិសាលភាពការងារបន្ថែមលើគម្រោងទីភ្នាក់ងារអភិវឌ្ឍន៍នានា ដោយបង្កើតជាកម្មវិធីតូចៗ ដែលអាចតាមដាន និងផ្តល់គុណតម្លៃបន្ថែម ដល់ការអនុវត្តការងារស្រូវអង្ករជួយលើកស្ទួយដល់ជីវភាពកសិករខ្មែរដែលមានដូចជា កម្មវិធីសមធម៌ពាណិជ្ជកម្មផ្នែកស្រូវអង្ករ (Rice Fair trade Program) កម្មវិធីគោលនយោបាយស្រូវនិរន្តរភាព (Sustainable Rice Platform) កម្មវិធីតាមដានការដាំដុះ (Rice Block chain) ជាដើម។

សហព័ន្ធស្រូវអង្ករកម្ពុជា សូមធ្វើការច្រានចោលទាំងស្រុងនូវការលើកឡើងនៅក្នុងញត្តិរបស់ក្រុមអតីតសកម្មជនគណបក្សសង្គ្រោះជាតិ ប្រចាំតំបន់មួយនៃប្រទេសអូស្ត្រាលី និងសូមស្នើសុំកុំឱ្យយកប្រជាកសិករធ្វើជាឈ្នាន់នយោបាយ និងបំផ្លាញទីផ្សារស្រូវអង្កររបស់កសិករ ហើយគួរណាស់តែគិតគូរជួយរកទីផ្សារជូនប្រជាកសិករខ្មែរវិញទើបជាការប្រសើរ។ សហព័ន្ធស្រូវអង្ករកម្ពុជាក៏សូមអំពាវនាវដល់ប្រជាកសិករនិងមហាជនទាំងក្នុងស្រុក និងក្រៅស្រុកសូមកុំឱ្យជឿតាមការប្រឌិត ការញុះញង់របស់ក្រុមជ្រុលនិយមទាំងនោះ។

សហព័ន្ធស្រូវអង្ករកម្ពុជាក៏ដូចជាកសិករខ្មែរទូទាំងប្រទេស សូមថ្លែងអំណរគុណដល់ប្រទេសនានាជាពិសេសប្រទេសអូស្ត្រាលីដែលបាន និងកំពុងជួយដល់វិស័យស្រូវអង្ករកម្ពុជាឱ្យមានភាពរីកចម្រើនមកដល់ពេលបច្ចុប្បន្ននេះ។

ថ្ងៃច័ន្ទ ១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០
**សហព័ន្ធស្រូវអង្ករកម្ពុជា**

CAMBODIA RICE FEDERATION